ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៧៧
ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩
សាលដីកា
លេខ : ១១៣ "ជ"
ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

### ក្រឡាបញ្ជី

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

ដើមចោទៈ អ្នកស្រី [redacted] ស្រីឡូន (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ ទីលំនៅសព្វថ្ងៃភូមិ-ឃុំ-ស្រុក សំរោង ខេត្តឧត្តរមានជ័យ។

ចុងចម្លើយៈលោក [redacted] បុត្រ (ចុងបណ្តឹងសាទុក្ខ) អាយុ ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅសព្វថ្ងៃភូមិឈូក ឃុំ-ស្រុក សំរោង ខេត្តឧត្តរមានជ័យ ។ តំណាងដោយលោក [redacted]



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា    Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia.



Scanned with CamScanner

157/3

អំពីវិវាទៈ ប្ដឹងសុំបដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ឧ.ជ ០០០៣០៨/២១-០៤-២០០៤ និង សុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ ២០ម គុណ ៣០ម

## អំពីអង្គហេតុ និង ចំណុចវិវាទៈ

ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ

តាមពាក្យបណ្ដឹងរបស់ដើមចោទអះអាងថា : កាលពីថ្ងៃទី ០៩-០៧-២០០៥ ខ្លួនបានទិញដីពីឈ្មោះ [redacted] សារ៉ាត់ និង ថ្ងៃទី ០៤-០៦-២០០៥ ខ្លួនទិញដីពីឈ្មោះ [redacted] ចាយ សរុបពីរប្លង់នេះមានទំហំ ២០ម គុណ ១១៥ម ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ០៤-០៦-២០០៥ និង ថ្ងៃទី ០៩-០៧-២០០៥ ហើយមានរបងស្រាប់ ។ ក្រោយពីទិញហើយ ខ្លួនបានធ្វើស្រែ និង ដាំដំណាំហូបផ្លែជាច្រើន លុះដល់ខែ ធ្នូ ឆ្នាំ ២០០៥ ស្រាប់តែមានទាហានមួយក្រុមមករុះរើរបងដីខ្លួន ហើយធ្វើរបងថ្មីយកដីខ្លួនអស់ទំហំ ២០ម គុណ ៣០ម ដោយអាងមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចលនវត្ថុលេខ ឧ.ជ ០០០៣០៨/២១-០៤-២០០៤។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៦ "ង" ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨ សាលាដំបូងខេត្តសៀមរាប-ឧត្ដរមានជ័យ សំរេចៈ

១-ច្រានចោលការទាមទាររបស់ឈ្មោះ [redacted] ស្រីឡូន ជាដើមចោទទាំងស្រុង។

២-ទទួលស្គាល់ការទាមទាររបស់ចុងចម្លើយ ដែលទាមទារអោយទទួលស្គាល់ដីទំហំ ៩០០ម² ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ឧ.ជ ០០០៣០៨ ចុះថ្ងៃទី ២១-០៤-២០០៤ ដែលមានព្រំប្រទល់ខាងជើងទល់ព្រំដីឈ្មោះ [redacted] សិទ្ធិ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ផ្លូវ និង ខាងលិចទល់ព្រំដីឈ្មោះ [redacted] សិទ្ធ ស្ថិតនៅភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្ដរមានជ័យ ជារបស់ [redacted] បុត្រ ជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] បុត្រ ។

៣-អោយដើមចោទឈ្មោះ [redacted] ស្រីឡូន បង់ជម្ងឺចិត្តចំនួន ៥០ម៉ឺនរៀល (ហាសិបម៉ឺនរៀល) ឱ្យទៅឈ្មោះ [redacted] បុត្រ ។ សុំលើសពីនេះលើកចោល។

៤-អោយឈ្មោះ [redacted] ស្រីឡូន ទទួលបន្ទុកប្រាក់ប្រដាប់ក្ដីទាំងអស់។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

សាមីខ្លួនមានសិទ្ធិប្ដឹងឧទ្ធរណ៍ ក្នុងរយៈពេលមួយខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] ស្រីឡូន ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ០៦ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ គ្រប់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។*



Scanned with CamScanner

57/3

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣០"គ" ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ របស់ សាលាឧទ្ធរណ៍

សំរេច :

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] ស្រីឡូន។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៦"ង" ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨ របស់ សាលាដំបូងខេត្ត សៀមរាប ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ ។ បើកផ្លូវប្តឹងសាទុក្ខ ក្នុងអំឡុងពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ស្រីឡូន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៥០ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u> :

ឈ្មោះ [redacted] ស្រីឡូន ធ្វើសេចក្តីថ្លែងការណ៍ថា : ដីទំនាស់រវាងខ្លួន– និង ចុងចម្លើយមាន ២ហិកតា។ នៅលើដីទំនាស់នេះខ្លួនមានផ្ទះ ហើយធ្វើស្រែ និង ដាំដំណាំ។ នៅឆ្នាំ ២០០៥ អ្នកកាន់កាប់នៅទីនោះបានលក់ដីឱ្យខ្លួនខ្លះ ដោយមានអាជ្ញាធរភូមិ-ឃុំដឹងឮ ហើយដីនេះម្ចាស់ដីដើមកាន់កាប់តាំងពីឆ្នាំ ៧៩មក ។ ក្រោយមកស្រាប់តែមានលោក[redacted] សុខុន មករុះរើរបង ដោយសំអាងលើប័ណ្ណកម្មសិទ្ធិរបស់គេ ដែលពីមុនអ្នកទាំងនេះពុំដែលមានមុខនៅលើដីនោះឡើយ។

សាលាដំបូងមិនបានកោះហៅសាក្សីខ្លួនទេ គឺកោះតែសាក្សីចុងចម្លើយមកឆ្លើយតែប៉ុណ្ណោះ ។ ឯសាលាឧទ្ធរណ៍បានកោះហៅតែ ២-៣ថ្ងៃមុនសវនាការប៉ុណ្ណោះ ហើយសំរេចអោយខ្លួនចាញ់ក្តីទៀត។

ឈ្មោះ[redacted] សុខុន ធ្វើសេចក្តីថ្លែងការណ៍ថា : នៅឆ្នាំ ២០០១ អាជ្ញាធរបានធ្វើការបែងចែកដីនេះជាឡូតិ៍ៗ។ ប្រវត្តិដីនេះពុំដូចការអះអាងរបស់ដើមចោទទេ តាមពិតម្តុំនេះជាសមរភូមិប្រយុទ្ធ រហូតដល់ឆ្នាំ ២០០០ ទើបឯកឧត្តម [redacted] ទីម ជាអភិបាលរងទី ១ បញ្ជាអោយដោះមីន ហើយដល់ថ្ងៃទី ៣០-៦-២០០១ ឯកឧត្តម ម៉ៅ ទីម បានប្រគល់ដីអោយតាមរយៈសំណើរបស់ខ្លួន ក្រោយពិនិត្យទៅឃើញថាដីពុំមានពាក់ព័ន្ធទេ ទើបនៅឆ្នាំ ២០០៤ រដ្ឋអំណាចចេញប័ណ្ណអោយខ្លួន ។ មុនចេញប្លង់ សុរិយោដីបានចុះអង្កេតជាច្រើនលើក-ច្រើនសារ ព្រោះខ្លាចប៉ះពាល់ដីអ្នកដទៃ។

ដីដែលដើមចោទទិញ គឺក្នុងភូមិកំណប់ ឃុំបន្ទាយរាក់ ឯដីទំនាស់ស្ថិតនៅភូមិឈូក ឃុំសំរោង។

ឈ្មោះ [redacted] ស្រីឡូន តប : ដែនដីរដ្ឋបាលទើបនឹងធ្វើការផ្លាស់ប្តូរឈ្មោះ ភូមិ-ឃុំនេះនៅឆ្នាំ ២០០៧

៥៧/២

ប៉ុណ្ណោះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ និង ចុងចម្លើយឈ្មោះ [redacted] សុខុម

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៥០ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ស្រីឡូន ធ្វើឡើងតាមកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ និង សាលាដំបូងសំរេចទទួលស្គាល់ដីទំនាស់ជារបស់ចុងចម្លើយនោះ ពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ដោយហេតុថា ដីទំនាស់នេះពុំទាន់មានគំនូសប្លង់បង្ហាញនៅឡើយទេ ។

-យល់ឃើញថា ខេត្តឧត្តរមានជ័យជាខេត្តបង្កើតថ្មី ហើយការអះអាងរបស់គូក្តីមានភាពខុសគ្នាអំពីទីតាំងដីដែលស្ថិតនៅនោះ ។ ចំណុចនេះ គប្បីមានរបាយការណ៍បញ្ជាក់អោយច្បាស់លាស់ពីអាជ្ញាធរខេត្តអំពីទីតាំងដីទំនាស់ស្ថិតនៅ និង ប្រវត្តិដីទំនាស់នេះ ។

-យល់ឃើញថា ចុងចម្លើយឈ្មោះ [redacted] បុត្រ បានដឹងដំណឹងអំពីការជំនុំជំរះរបស់តុលាការកំពូលហើយ តែមិនចូលខ្លួនទេ ប៉ុន្តែមានសារណាការពារដាក់មកតុលាការកំពូលរួចហើយ តុលាការកំពូលអាចជំនុំជំរះបាន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣០ "គ" ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៥០ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] ស្រីឡូន ជាដើមចោទ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ៣០ "គ" ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ របស់ សាលាឧទ្ធរណ៍ ចោលជាអសារបង់ ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២៧៧ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ របស់ តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។



Scanned with CamScanner

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ ចុងចម្លើយ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ។

ឯកឧត្តម [redacted] ប្រធាន
លោក ចៅក្រម
លោក ចៅក្រម
លោក ចៅក្រម
លោកស្រី ចៅក្រម
លោកស្រី ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

Scanned with CamScanner